ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០០៣.....សហវ.-ហវ

រាជធានីភ្នំពេញ,ថ្ងៃទី២៤ ខែ មករា ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង
# ស្តីពីការអនុវត្តចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក

យោងអនុក្រឹត្យលេខ ១៧២អនក្រ.បក ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក និងសារាចរណែនាំលេខ ០០៨សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមបញ្ជាក់អំពីនីតិវិធីនៃការអនុវត្តចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក ដូចខាងក្រោម៖

១-ការសន្យាចំណាយ : គឺជាលិខិតស្នើសុំដែលរៀបចំឡើង និងចុះហត្ថលេខាដោយប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក នឹងត្រូវបានអាណាប័កឬអាណាប័កផ្ទេរសិទ្ធិចុះហត្ថលេខាឯកភាព។

២-ក្រោយពីបានឯកភាពនិងចុះហត្ថលេខាលើលិខិតស្នើសុំសន្យាចំណាយ អាណាប័កឬអាណាប័កផ្ទេរសិទ្ធិត្រូវចុះហត្ថលេខាលើសលាកប័ត្រកត់ត្រាចំណាយថវិកានិងត្រួតពិនិត្យហិរញ្ញវត្ថុ ដោយរក្សាទុកទំនេរកន្លែងហត្ថលេខារបស់អភិបាលហិរញ្ញវត្ថុ ហើយបញ្ជូនទៅអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

៣-ក្រោយពីកិច្ចជំរះបញ្ជីត្រូវបានបញ្ចប់ ការបោះផ្សាយអាណត្តិសម្រាប់ទូទាត់រាល់ការចំណាយទាំងអស់ត្រូវចុះហត្ថលេខាអាណាប័កឬអាណាប័កផ្ទេរសិទ្ធិដោយរក្សាទំនេរកន្លែងហត្ថលេខារបស់អភិបាលហិរញ្ញវត្ថុ។

៤-អាណត្តិបើកប្រាក់ និងឯកសារពាក់ព័ន្ធទាំងអស់ត្រូវបញ្ជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីត្រួតពិនិត្យថវិកានិងចុះហត្ថលេខាកន្លែងអភិបាលហិរញ្ញវត្ថុដោយប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកទទួលសិទ្ធិមិនឲ្យលើស៣ថ្ងៃការងារ។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមលោក លោកស្រីប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានរតនាគារ និងនាយកទីចាត់ការហិរញ្ញវត្ថុខេត្ត ដែលជាក្រុមការងារគាំទ្រការរៀបចំ និងអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក មេត្តាជ្រាប និងសម្របសម្រួលដល់រាល់កិច្ចដំណើរការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុកឲ្យប្រព្រឹត្តទៅដោយសង្គតភាព។ ក្នុងករណីជួបបញ្ហាប្រឈម ត្រូវរាយការណ៍ជាបន្ទាន់មកនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល**
-អគ្គនាយកដ្ឋានរតនាគារជាតិ
-គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-គ្រប់រតនាគារខេត្ត
-គ្រប់នាយកទីចាត់ការហិរញ្ញវត្ថុខេត្ត
«ដើម្បីសម្របសម្រួល»
-ឯកសារ